ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ: ធ៧ ០១៥ ០០៨ ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខណៈសម្គាល់នៃធនប័ត្រ ប្រភេទ ៥០០ រៀល គំរូថ្មី

***********

អនុលោមតាមអនុក្រឹត្យលេខ ០៥ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៥ ស្តីពីការចេញផ្សាយធនប័ត្រប្រភេទ ៥០០ រៀល គំរូថ្មីក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជាសូមប្រកាសផ្សាយជាសាធារណៈ នូវលក្ខណៈសំគាល់នៃធនប័ត្រគំរូថ្មីនេះ មានដូចខាងក្រោម ៖

**ក- លក្ខណៈទូទៅ ៖**

- ទំហំធនប័ត្រ ៖ បណ្តោយ ១៣៨ មម និងទទឹង ៦៤ មម
- ពណ៌ចម្បង គឺពណ៌ក្រហមស្រស់ និងពណ៌ត្នោត ។

**ខ- ផ្ទៃខាងមុខ ៖**

- **ផ្នែកកណ្តាល** ខាងស្តាំត្រូវបានរំលេចឡើងនូវព្រះឆាយាល័ក្ខណ៍នៃ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តមសីហមុនី** មើលពីមុខបញ្ឆិតចំហៀងខាងឆ្វេង ខាងឆ្វេងមានលេខ " ៥០០ " នៅពីលើគេ បន្ទាប់មកគឺជាហត្ថលេខារបស់ទេសាភិបាលនិងអគ្គបេឡា ព្រមទាំងរូបព្រះសង្ហារនៃព្រះរាជាណាចក្រកម្ពុជា និងនៅពីក្រោមមានលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ រូបចម្លាក់នាគក្បាល ៥ និងអក្សរ " ប្រាំរយរៀល " ព្រមទាំងអក្សរ " អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់ " នៅគែមខាងក្រោមនោះ ។
- **ផ្នែកខាងស្តាំ** ជ្រុងលើមានអក្សរ " ធនាគារជាតិនៃកម្ពុជា " ព្រមទាំងលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហម និងជ្រុងក្រោមមានលេខ "៥០០" ព្រមជាមួយលេខ "500" នៅពីក្រោមនោះ ។
- **ផ្នែកខាងឆ្វេង** មានលេខ "500" ព្រាលៗបោះពុម្ពតាមបន្ទាត់បញ្ឈរ ព្រមទាំងរូបភាពក្បាច់លំអពណ៌ប្រាក់បោះពុម្ពកាត់ទទឹងក្រដាសប្រាក់ពីលើដល់ក្រោម និងជ្រុងក្រោមមានគំនូសបន្ទាត់ខ្លីៗជាច្រើនបង្កើតឡើងដោយលេខ "៥០០" ដ៏តូចល្អិត ។

**គ- ផ្ទៃខាងខ្នង ៖**

- **ផ្នែកកណ្តាល** រូបភាពត្រូវបានរំលេចឡើងគឺជាស្ពានគីហ្សូណាឆ្លងកាត់ទន្លេមេគង្គនៅក្រុងកំពង់ចាម ខាងលើមានរូបភាពក្បាច់ចម្លាក់នៅជញ្ជាំងប្រាសាទបាយ័នស្តីពីសកម្មភាព

សាងសង់ និងខាងក្រោមមានអក្សរ " ប្រាំរយរៀល " ។

**- ផ្នែកខាងស្តាំ** ជ្រុងលើមានលេខ " 500 " បោះពុម្ពតាមបន្ទាត់បញ្ឈរ នៅកណ្តាលមានរូបស្តូបអនុស្សាវរីយ៍មិត្តភាពកម្ពុជា-ជប៉ុនដែលបិតនៅក្បាលស្ពានគីហ្សូណា និងនៅជ្រុងក្រោមមានលេខ " ៥០០ " ។

**- ផ្នែកខាងឆ្វេង** ជ្រុងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" អក្សរ " NATIONAL BANK OF CAMBODIA " និងលេខ " 2014 " នៅកណ្តាលមានរូបភាពព្រាលៗនៃផ្នែកកណ្តាលរបស់ស្ពានឆ្លងកាត់ទន្លេមេគង្គនៅអ្នកលឿង ព្រមទាំងក្បាច់លំអពណ៌ប្រាក់ផ្តុំឡើងដោយលេខ " ៥០០ " បញ្ច្រាស់គ្នា និងនៅជ្រុងក្រោមមានលេខ " ៥០០ " ។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រប្រភេទ ៥០០ រៀល គំរូថ្មីត្រូវបានដាក់ឲ្យចរាចរទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀតដែលត្រូវបានចេញផ្សាយរួចមកហើយ ។ សាធារណជនគ្រប់រូបត្រូវពិនិត្យ-សម្គាល់ធនប័ត្រថ្មីនេះឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភ័ន្តច្រឡំ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៥

**ទេសាភិបាល**

**ជា.ចាន់តូ**